**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៩៨ សហវ

លិខិតចូល
ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៧

# ប្រកាស

## ស្តីពី

## ការផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនធានារ៉ាប់រងទូទៅ ឬអាយុជីវិត

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើប្រាស់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០០១ ស្តីពីការណែនាំអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ បក ចុះថ្ងៃទី ២០ ខែមករា ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨/អនក្រ បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ២០០០ បំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៥៨៤ សហវ ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសំរួលការរៀបចំ និងប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- បានឃើញការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

### ជំពូក ១ : បទប្បញ្ញត្តិទូទៅ

**ប្រការ ១ :** តាមការឱ្យនិយមន័យនៅក្នុងជំពូក១ នៃច្បាប់ស្តីពីការធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងគឺជានីតិបុគ្គលដែលបង្កើតឡើងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទទួលហានិភ័យធានារ៉ាប់រងក្រោមកិច្ចសន្យាធានារ៉ាប់រង ហើយនិងត្រូវទទួលអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុនពេលចាប់ផ្តើមអាជីវកម្ម ។

**ប្រការ ២ :** អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណធានារ៉ាប់រង ត្រូវជ្រើសរើសយកទម្រង់គតិយុត្តិមួយ ដែលមានចែងនៅក្នុងជំពូក ៤ នៃច្បាប់ស្តីពីការធានារ៉ាប់រង ។ ចំពោះក្រុមហ៊ុនធានារ៉ាប់រងថ្មីដែលនិងទទួលអាជ្ញាប័ណ្ណក្រោមខ្លឹមសារនៃប្រកាសនេះ ត្រូវមានភាគទុនិកយ៉ាងតិច ៣ ។

**ប្រការ ៣ :** មុនពេលទទួលអាជ្ញាប័ណ្ណ អ្នកដាក់ពាក្យស្នើសុំ ត្រូវផ្តល់លិខិត ឬឯកសារដែលបញ្ជាក់អះអាងថាបានបំពេញតាមលក្ខខណ្ឌ ដែលមានចែងនៅក្នុងមាត្រាទី ៤៨ នៃច្បាប់ស្តីពីការធានារ៉ាប់រង ដូចខាងក្រោមនេះ :

ក- បានរក្សាប្រាក់ដំកល់ចំនួនស្មើនឹងដប់ (១០)ភាគរយនៃដើមទុនចុះបញ្ជី។

ខ- បានរក្សាកំរិតសាធនភាពចំនួនស្មើនិង ហាសិប (៥០)ភាគរយនៃដើមទុនចុះបញ្ជី។

### ជំពូក ២ : នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាប័ណ្ណ និងការសុំបន្តអាជ្ញាប័ណ្ណ

**ប្រការ ៤ :** បុគ្គលដែលទទួលបានការអនុញ្ញាតត្រឹមត្រូវ (សមាជិកក្រុមប្រឹក្សាភិបាល អគ្គនាយក ឬបុគ្គលផ្សេងទៀតដែលមានសិទ្ធិក្នុងការដាក់ពាក្យសុំអាជ្ញាប័ណ្ណ) ត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ដោយបំពេញទម្រង់បែបបទ ដែលទទួលពីនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវបង្ហាញពត៌មានដូចតទៅ :

**ក- ពត៌មានអំពីក្រុមហ៊ុន**

១) ឈ្មោះក្រុមហ៊ុនធានារ៉ាប់រង ។

២) អាសយដ្ឋានរបស់ទីស្នាក់ការកណ្តាលក្រុមហ៊ុន ឬការិយាល័យសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៣) ទម្រង់គតិយុត្តិ លក្ខន្តិកៈបង្កើតក្រុមហ៊ុន បទបញ្ជាផ្ទៃក្នុង ឬ លិខិតបទដ្ឋានផ្សេងទៀត។

៤) ប្រភេទមូលប័ត្រដែលជាដើមទុននិងទំនាក់ទំនងរវាងម្ចាស់មូលប័ត្រ និងការអនុវត្តន៍សិទ្ធិបោះឆ្នោត។

៥) ចំនួនទឹកប្រាក់ដើមទុនចុះបញ្ជីដែលមានស្រាប់ ដើមទុនចុះបញ្ជីដែលគ្រោងទុក និងដើមទុនដែលបានបង់ ។

៦) ការបែងចែកភាគហ៊ុន និងសិទ្ធិបោះឆ្នោត កិច្ចព្រមព្រៀងផ្សេងៗរវាងភាគទុនិកក្នុងគោលបំណងតម្រង់ទិសគោលនយោបាយរបស់ក្រុមហ៊ុនធានារ៉ាប់រង។

៧) ភាគទុនិកដែលមានសិទ្ធិបោះឆ្នោតចាប់ពីដប់ (១០)ភាគរយឡើងទៅ ត្រូវផ្តល់ពត៌មានដែលមានរៀបរាប់នៅក្នុងប្រការ ៥ នៃប្រកាសនេះ។

៨) អត្តសញ្ញាណរបស់បុគ្គល (យ៉ាងតិចពីររូប) ដែលទទួលខុសត្រូវលើដំណើរការអាជីវកម្មធានារ៉ាប់រង ឬការគ្រប់គ្រងមុខងារសំខាន់ៗ (ដូចជា មុខងារលក់ សំណង វាយតម្លៃហានិភ័យ និងគណនេយ្យ)។ អ្នកគ្រប់គ្រងទាំងនេះ ត្រូវផ្តល់ពត៌មានដែលមានចែងនៅក្នុងប្រការ៦ នៃប្រកាសនេះ ហើយប្រធានសាខារបស់ក្រុមហ៊ុនធានារ៉ាប់រងបរទេសនៅកម្ពុជា ត្រូវតែងតាំងដោយអ្នកគ្រប់គ្រងដែលមានសមត្ថកិច្ចនៃទីស្នាក់ការកណ្តាល។

៩) អត្តសញ្ញាណរបស់សមាជិក ដែលមានសិទ្ធិធ្វើការសម្រេចចិត្ត និង ពត៌មានដែលតម្រូវនៅក្នុងប្រការ ៦ នៃប្រកាសនេះ។

១០) ប្រសិនបើអ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ គឺជានីតិបុគ្គល ដែលបានបង្កើតរួចមកហើយ ត្រូវផ្តល់ការពិពណ៌នាអំពីអាជីវកម្មរបស់ខ្លួន និងថតចម្លងរបាយការណ៍ហិរញ្ញវត្ថុសវនកម្មបី (៣) ឆ្នាំចុងក្រោយ ។

**ខ- ផែនការអាជីវកម្ម**

ការពិពណ៌នាអំពីផែនការសកម្មភាពសម្រាប់រយៈពេលបី (៣)ឆ្នាំ បន្តបន្ទាប់ :

១) ប្រភេទ និងទំហំនៃសេវាដែលបានធានារ៉ាប់រង និងការប៉ាន់ប្រមាណអំពីតម្រូវការធានារ៉ាប់រងបន្ត។

២) ប្រភេទ និង ទំហំនៃសេវាដែលផ្តល់ចំពោះអតិថិជនផ្សេងទៀត ដូចជា ការគ្រប់គ្រងហានិភ័យ ការបង្ការការខូចខាតជាដើម។

៣) ប្រភេទអតិថិជន (បុគ្គល ក្រុមហ៊ុន អង្គការអន្តរជាតិ) ដែលក្រុមហ៊ុនធានារ៉ាប់រងចង់បាន។

៤) ប្រភេទធនធានហិរញ្ញវត្ថុគ្រោងទុក ដែលអាចជាមូលនិធិផ្ទាល់ខ្លួន បុរេប្រទានរបស់ភាគទុនិក ឥណទានធនាគារ ឬ ឥណទានផ្សេងទៀត។

៥) ចំណាយអភិវឌ្ឍន៍សម្រាប់បង្កើតក្រុមហ៊ុន។

៦) ចំនួនបុគ្គលិកសម្រាប់រយៈពេលបី (៣)ឆ្នាំ បន្តបន្ទាប់ ដោយផ្តល់ព័ត៌មានលំអិតអំពីប្រភេទបុគ្គលិក។

៧) ចំនួន និងទីតាំងនៃការិយាល័យសាខា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៨) តារាងតុល្យការ និងរបាយការណ៍លទ្ធផលព្យាករណ៍សម្រាប់ការិយបរិច្ឆេទបី (៣)ឆ្នាំបន្តបន្ទាប់។

**គ- សវនកម្មផ្ទៃក្នុង**

១) រចនាសម្ព័ន្ធសវនកម្មផ្ទៃក្នុងដែលមានស្រាប់ និងគ្រោងទុក ដើម្បីធានាដល់ការបំពេញលក្ខខណ្ឌដែលតម្រូវដោយបទប្បញ្ញត្តិហិរញ្ញវត្ថុ។

២) វិធីសាស្ត្រក្នុងការដាក់កម្រិតលើប្រភេទហានិភ័យនីមួយៗ និង នីតិវិធីដែលបានគ្រោងទុក ដើម្បីធានាដល់ការប្រព្រឹត្តតាមច្បាប់ រួមទាំងការដាក់កម្រិតសិទ្ធិអំណាចរបស់ភ្នាក់ងារ។

៣) នីតិវិធីដែលបានគ្រោងទុក ដើម្បីបង្កើត និងធានាផលស្តង់ដាក្រមសីលធម៌វិជ្ជាជីវៈដែលទាក់ទងនឹងសកម្មភាពលក់ និងការប្រកួតប្រជែងស្មើភាព។

៤) សមាសភាព និង ភារៈកិច្ចរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

**ឃ- សវនកម្មឯករាជ្យ**

១) អត្តសញ្ញាណរបស់សវនករដែលបានស្នើឡើងត្រូវមាននៅក្នុងបញ្ជីឬត្រូវបញ្ចូលក្នុងបញ្ជីសវនករឯករាជ្យរបស់ក្រុមហ៊ុនធានារ៉ាប់រង។

២) ប្រភេទនៃការងាររបស់សវនករ។

**ង- គំរូប័ណ្ណសន្យាធានារ៉ាប់រង**

គំរូប័ណ្ណសន្យារ៉ាប់រង និងប័ណ្ណផ្សព្វផ្សាយដែលនឹងប្រើប្រាស់។

**ច- លក្ខខណ្ឌបន្ថែមសម្រាប់សាខា ឬ បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនធានារ៉ាប់រងបរទេស**

១) ការពិពណ៌នាអំពីនីតិវិធីសម្រាប់ការត្រួតពិនិត្យរបស់ក្រុមហ៊ុនមេ លើសាខា ឬលើបុត្រសម្ព័ន្ធបរទេស។

២) ការពិពណ៌នាអំពីការគ្រប់គ្រងលើសាខា ឬបុត្រសម្ព័ន្ធបរទេស ដោយអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងប្រទេសដើម។

៣) តារាងតុល្យការ និងរបាយការណ៍លទ្ធផលសវនកម្ម សម្រាប់រយៈពេលបី(៣)ឆ្នាំចុងក្រោយ។

៤) របាយការណ៍ហិរញ្ញវត្ថុសវនកម្មសម្រាប់រយៈពេលបីឆ្នាំដែលបានបញ្ជាក់ដោយសវនករឯករាជ្យនៃប្រទេសដើម។

៥) ការបង្ហាញពីទីតាំងនៃសាខាដែលក្រុមហ៊ុនមានបំណងបង្កើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៦) លិខិតផ្តល់សិទ្ធិ ដែលបានបកប្រែស្តីពីការធ្វើអាជីវកម្មនៅក្នុងប្រទេសដើម។

៧) ពត៌មាន និងលិខិតអនុញ្ញាតពីនិយ័តករនៃប្រទេសដើមដែលបញ្ជាក់ថា ក្រុមហ៊ុនធានារ៉ាប់រងមានលទ្ធភាពទូទាត់សំណង និងបំពេញបានតាមលក្ខខណ្ឌរបស់និយ័តករ នៃប្រទេសដើមជាភាសាខ្មែរ។

៨) លិខិតតែងតាំងនីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានលក្ខណៈវិនិច្ឆ័យសមស្រប ក្នុងការគ្រប់គ្រងសាខានៅក្នុងប្រទេសកម្ពុជា។

៩) លក្ខខណ្ឌពតិមាននៅក្នុងប្រការ ៦ ព្រមទាំងជីវប្រវត្តិសង្ខេប និង លិខិតថ្កោលទោសពីប្រទេសដើមរបស់បុគ្គលទាំងឡាយ ដែលនឹងមកគ្រប់គ្រងការិយាល័យសាខាណាមួយ។

១០) ឯកសារផ្សេងទៀតដែលតម្រូវដោយនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ៩: ភាគទុនិកដែលកាន់កាប់ដើមទុន ឬសិទ្ធិបោះឆ្នោតចាប់ពីដប់ (១០)ភាគរយឡើងទៅ ត្រូវផ្តល់

ពត៌មានដូចខាងក្រោមនេះ :

ក- អត្តសញ្ញាណរបស់ភាគទុនិក

១) ក្នុងករណីជានីតិបុគ្គល : បង្ហាញឈ្មោះ ទម្រង់គតិយុត្តិ និងអាស័យដ្ឋាននៃទីស្នាក់ការកណ្តាល។

២) ក្នុងករណីជារូបវន្តបុគ្គល នាមត្រកូលនិងនាមខ្លួន ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត សញ្ជាតិ (ឬសញ្ជាតិទីពីរ ប្រសិនបើមាន) និងអាស័យដ្ឋាននៃប្រទេសដើម ។

៣) រាល់ភាគទុនិក ឬ អគ្គនាយកនៃនីតិបុគ្គល ត្រូវផ្តល់ជីវប្រវត្តិសង្ខេប និងបំពេញព័ត៌មាន ដែលមានចែងនៅក្នុងប្រការ ៦។

ខ- បង្ហាញចំនួន ឬ ភាគរយនៃការចូលរួមទុន ឬសិទ្ធិបោះឆ្នោតសមមូលៈ ពិពណ៌នាកិច្ចព្រមព្រៀងគតិយុត្តិ និងហិរញ្ញវត្ថុនៃការទិញមូលប័ត្រទាំងនោះ ។ ប្រសិនបើភាគទុនិក គឺជារូបវន្តបុគ្គលត្រូវបញ្ជាក់ពីប្រភពនៃដើមទុនដែលយកមកទិញមូលប័ត្រនោះ ។ បញ្ជាក់ថា តើការទិញលក់មូលប័ត្រនោះ ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ឬបទប្បញ្ញត្តិឬទេដូចជា ទម្រង់ច្បាប់ដែលទាក់ទងនឹងការវិនិយោគបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

គ- បង្ហាញពីការបែងចែកភាគហ៊ុនរបស់ភាគទុនិកៈ ប្រសិនបើមាន គួរបញ្ជាក់ពីការបែងចែកភាគហ៊ុនរបស់ក្រុមហ៊ុនមេ និងក្រុមហ៊ុនភាគទុនិកហើយផ្តល់ ព័ត៌មានអំពីភាគរយនៃភាគហ៊ុន និងសិទ្ធិបោះឆ្នោត។ ផ្តល់បញ្ជីឈ្មោះនៃអគ្គនាយក និងអ្នកគ្រប់គ្រង ផ្សេងទៀតរបស់ភាគទុនិក។

ឃ- ពិពណ៌នាសកម្មភាពរបស់ភាគទុនិកៈ ប្រសិនបើភាគទុនិក គឺជាផ្នែកមួយនៃសម្ព័ន្ធក្រុមហ៊ុនសូមផ្តល់ការពិពណ៌នាអំពីក្រុមហ៊ុនសំខាន់ៗនៃសម្ព័ន្ធនោះ ព្រមទាំងរចនាសម្ព័ន្ធផ្សេងៗ ។ បង្ហាញថា តើភាគទុនិកមានភាគហ៊ុននៅក្រុមហ៊ុនធានារ៉ាប់រង ឬក្នុងស្ថាប័នធនាគារផ្សេងទៀតឬទេ ។ បង្ហាញថាតើសម្ព័ន្ធក្រុមហ៊ុនមានភាគហ៊ុននៅក្នុង ក្រុមហ៊ុនធានារ៉ាប់រង ឬស្ថាប័ន ធនាគារឬទេ ហើយបើមានសូមបញ្ជាក់ពីភាគហ៊ុនទាំងនោះ។

ង- បង្ហាញថាតើភាគទុនិករូបនោះ និងក្រុមហ៊ុនដែលអាចពាក់ព័ន្ធទាំងឡាយ ធ្វើអាជីវកម្មធានារ៉ាប់រង និង ធនាគារឬទេ ហើយបើដូច្នោះមែន បង្ហាញពីបទប្បញ្ញត្តិ និងអាជ្ញាធរទាំងឡាយដែលពាក់ព័ន្ធ ។

**ប្រការ ៦ :** បុគ្គលនីមួយៗដែលបានកំណត់ក្នុងប្រការ ៤ និងជាអ្នកកាន់តំណែងគ្រប់គ្រង ដូចមានចែងនៅក្នុងប្រការ ៥ ត្រូវផ្តល់ព័ត៌មាន ជីវប្រវត្តិសង្ខេប និងកម្រងសំណួរ ដូចខាងក្រោមនេះ :

ក- អត្តសញ្ញាណរបស់អ្នកគ្រប់គ្រង

១) នាមត្រកូល និងនាមខ្លួន ។

២) ថ្ងៃខែឆ្នាំ និង ទីកន្លែងកំណើត ។

៣) សញ្ជាតិ ។

៤) អាស័យដ្ឋានរបស់បុគ្គល(ទីកន្លែងស្នាក់នៅ បន្ទាប់ពីទទួលការតែងតាំងនិង ក្នុងករណីមានអាស័យដ្ឋានខុសគ្នា អ្នកគ្រប់គ្រងគួរតែស្នាក់នៅទីកន្លែងធ្វើអាជីវកម្មដូចជា នៅក្នុងប្រទេស

កម្ពុជា ជាដើម) ។

ខ- ប្រវត្តិនៃការសិក្សា និង បទពិសោធន៍

១) កម្រិតវប្បធម៌ ព្រមទាំង ថ្ងៃខែឆ្នាំ និងទីកន្លែងទទួលសញ្ញាប័ត្រ ។

២) បទពិសោធន៍ការងារក្នុងរយៈពេលដប់(១០)ឆ្នាំចុងក្រោយរួមទាំង ឈ្មោះ ទីកន្លែង និងសកម្មភាពអាជីវកម្មរបស់និយោជក ប្រភេទបទពិសោធន៍ដែលទទួលបាននិងទំហំនៃការទទួលខុសត្រូវ។

គ- បង្ហាញថាតើ ក្នុងការអនុវត្តន៍ភារកិច្ច លោកអ្នកនឹងគោរពតាមការណែនាំរបស់បុគ្គល ឬក្រុមហ៊ុនផ្សេងក្រៅពីអ្នកស្នើសុំអាជ្ញាប័ណ្ណឬទេ ដែលក្នុងករណីណាក៏ដោយ សូមផ្តល់ពតិមានដែលពាក់ព័ន្ធទាំងអស់ ។

ឃ- ពិពណ៌នារាល់កិច្ចការគ្រប់គ្រងដែលលោកអ្នកនឹងទទួលខុសត្រូវដោយផ្ទាល់ ។

ង- បង្ហាញថាតើ លោកអ្នកគឺជា ឬធ្លាប់ជាភាគទុនិកសំខាន់មួយរូប ក្នុងអំឡុងពេល ១០ ឆ្នាំចុងក្រោយ (មានភាគហ៊ុននិងសិទ្ធិបោះឆ្នោត ចាប់ពីដប់(១០)ភាគរយ ឡើងទៅ) នៃក្រុមហ៊ុនមួយ ឬច្រើន និងចំនួនភាគហ៊ុន ដែលលោកអ្នកបានកាន់កាប់ ។

ច- បង្ហាញពីទំនាក់ទំនងរវាងក្រុមហ៊ុនដែលលោកអ្នកធ្លាប់ទទួលខុសត្រូវឬធ្លាប់មានភាគហ៊ុន និង អ្នកដាក់ ពាក្យសុំអាជ្ញាប័ណ្ណ ។

ឆ- បង្ហាញថាតើលោកអ្នកធ្លាប់ពាក់ព័ន្ធនឹងបណ្តឹងតវ៉ាផ្នែករដ្ឋបាល វិជ្ជាជីវៈ តុលាការ ដែលនាំអោយជាប់ទោសទណ្ឌផ្សេងៗ ទាំងនៅក្នុងប្រទេសកម្ពុជា និងនៅបរទេសដោយសូមបង្ហាញរាល់ពតិមានលំអិតដែលពាក់ព័ន្ធ។

ជ- បង្ហាញថា តើលោកអ្នកមានទំនាក់ទំនងល្អជាមួយម្ចាស់កម្ចី ស្ថាប័នតុលាការ ស្ថាប័នក្រៅប្រព័ន្ធតុលាការនៅកម្ពុជានិងនៅបរទេស ដើម្បីសំរួលដល់ការដោះស្រាយបំណុលដែលលោកអ្នកមិនអាចគោរពបានតាមការសន្យាពីមុនមក ។ បញ្ជាក់ថាតើលោកអ្នកដឹងអំពីបណ្តឹងណាមួយ ដែលពាក់ព័ន្ធក្រុមហ៊ុនទាំងឡាយ ដែលលោកអ្នកមានភាគហ៊ុនច្រើននៅក្នុងក្រុមហ៊ុនទាំងនោះ ដោយសូមផ្តល់រាល់ពតិមានលំអិតដែលពាក់ព័ន្ធ ។

ឈ- បង្ហាញថាតើ លោកអ្នកធ្លាប់បានទទួលការពិន័យ ឬបណ្តេញចេញដោយនិយោជកឬទេ ហើយបើសិនជាមាន សូមផ្តល់រាល់ពតិមានលំអិត ។

ញ- បង្ហាញថា តើលោកអ្នកមានភាគហ៊ុននៅក្នុងក្រុមហ៊ុន ដែលកំពុងដាក់ពាក្យសុំអាជ្ញាប័ណ្ណ ឬមានបំណងដោយផ្ទាល់ ឬតាមរយៈអន្តរការី ដើម្បីទិញយកភាគហ៊ុនពីក្រុមហ៊ុនដែលកំពុងស្នើសុំអាជ្ញា-ប័ណ្ណ ឬទេ ។

ដ- សូមផ្តល់រាល់ពតិមានបន្ថែមជូនទៅនិយ័តករធានារ៉ាប់រងទាក់ទងនឹងសមត្ថភាព និងការកាន់តំណែងគ្រប់គ្រង នៅក្នុងក្រុមហ៊ុនដែលកំពុងសុំអាជ្ញាប័ណ្ណ ។

**ជំពូក ៣ : ការអនុញ្ញាត និង សោហ៊ុយពាក់ព័ន្ធ**

**ប្រការ ៧ :** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសម្រេចចិត្តក្នុងរយៈពេល ៤៥ ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានពាក្យសុំអាជ្ញាប័ណ្ណ រួមទាំងរាល់ឯកសារពាក់ព័ន្ធ ។ ក្នុងករណីចាំបាច់ការអនុញ្ញាតដោយភ្ជាប់នូវលក្ខខណ្ឌពិសេសណាមួយ នឹងត្រូវផ្តល់ជូនដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយបញ្ជាក់នូវកាលកំណត់អំពីការបំពេញលក្ខខណ្ឌនេះ។ ក្នុងករណីដែលលក្ខខណ្ឌមិនត្រូវបំពេញតាមកាលកំណត់ទេនោះ ហើយដោយពុំមានការពន្យាការអនុញ្ញាត ដោយភ្ជាប់លក្ខខណ្ឌនឹងត្រូវអស់សុពលភាពដោយឯកឯង ហើយពុំមានការចេញអាជ្ញាប័ណ្ណដូចនេះទៀតទេ។

**ប្រការ ៨ :** អាជ្ញាប័ណ្ណមានសុពលភាពសម្រាប់រយៈពេលបី (៣)ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាប័ណ្ណ។ អាជ្ញាប័ណ្ណនេះអាចស្នើសុំបន្តបានសម្រាប់រយៈពេលបី(៣)ឆ្នាំម្តង លុះត្រាណាតែក្រុមហ៊ុនបានអនុវត្តត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញាតិជាធរមាន ។ សោហ៊ុយអាជ្ញាប័ណ្ណមានចំនួនហាសិបលាន (៥០) រៀល ។

**ប្រការ ៩ :** គ្រប់ក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើការទូទាត់ជាកាតព្វកិច្ចទៅរាជរដ្ឋាភិបាល តាមការកំណត់ដូចខាងក្រោម :

ក) ក្រុមហ៊ុនធានារ៉ាប់រង ត្រូវបង់ពន្ធទៅរតនាគារជាតិ ដូចមានចែងនៅក្នុងច្បាប់ស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ។

ខ) ក្រុមហ៊ុនធានារ៉ាប់រងត្រូវបង់ ០,៥ភាគរយ នៃបុព្វលាភដុល ទៅនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ដើម្បីទូទាត់លើចំណាយក្នុងការផ្សព្វផ្សាយសម្រាប់អភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជា ។

**ជំពូក ៤ : ការពន្យារ និងការដកហូតអាជ្ញាប័ណ្ណ**

**ប្រការ ១០ :** រដ្ឋមន្ត្រី អាចដកហូតអាជ្ញាប័ណ្ណពីក្រុមហ៊ុនធានារ៉ាប់រងតាមសំណើរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រសិនបើ :

ក) ក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណឱ្យធ្វើអាជីវកម្ម បានបញ្ឈប់ការលក់ប័ណ្ណសន្យាធានារ៉ាប់រងថ្មីដូចបានកំណត់ឡើងក្នុងអាជ្ញាប័ណ្ណ ។

ខ) ក្រុមហ៊ុនដែលកំពុងធ្វើអាជីវកម្ម ធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់អតិថិជន ។

គ) ក្រុមហ៊ុនបាន និងកំពុងប្រព្រឹត្តល្មើសទៅនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការធានារ៉ាប់រង និង បទប្បញ្ញត្តិដទៃទៀត ។

ឃ) ក្រុមហ៊ុនធានារ៉ាប់រង ឬនាយក ឬបុគ្គលិកទទួលខុសត្រូវគ្រប់គ្រង បានផ្តល់ព័ត៌មានមិនពិតមិនជាក់លាក់ ឬបានបិទបាំង ឬមិនបង្ហាញការពិតនៅក្នុងពាក្យស្នើសុំអាជ្ញាប័ណ្ណ ដែលមានចែងនៅក្នុងប្រកាសនេះ ។

ង) ក្រុមហ៊ុនធានារ៉ាប់រង ឬនាយក ឬបុគ្គលិកទទួលខុសត្រូវគ្រប់គ្រង ត្រូវបានផ្តន្ទាទោសពីការប្រព្រឹត្តល្មើសទៅនឹងច្បាប់ធានារ៉ាប់រង ឬបទប្បញ្ញត្តិផ្សេងទៀត ឬការប្រព្រឹត្តល្មើសដែលទាក់ទងនឹងការក្លែងបន្លំ ឬការមិនស្មោះត្រង់ដូចមានចែងនៅក្នុងច្បាប់ និងបទបញ្ញាតិជាធរមានផ្សេងៗ ។

ច) ក្រុមហ៊ុនធានារ៉ាប់រង មិនមានលទ្ធភាពបំពេញកាតព្វកិច្ចហិរញ្ញវត្ថុ ឬកាតព្វកិច្ចផ្សេងទៀត ។

ឆ) ក្រុមហ៊ុនធានារ៉ាប់រង បាននិងកំពុងសម្រុះសម្រួលដោះស្រាយជាមួយម្ចាស់បំណុល ឬបានឈានចូលដល់ដំណាក់កាលដែលត្រូវជម្រះបញ្ជី ឬត្រូវបានរំលាយតាមរបៀបផ្សេងទៀត ។

ជ) ក្រុមហ៊ុនធានារ៉ាប់រង ដែលស្ថិតក្នុងករណីមានសាលក្រមរបស់តុលាការតែងតាំងឱ្យមានអ្នកមកទទួល ឬគ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននោះ ។

ឈ) កម្មសិទ្ធិលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ត្រូវបានប្រគល់ទៅឱ្យម្ចាស់បំណុល ឬអ្នកតំណាងរបស់ម្ចាស់បំណុល ទៅតាមបន្ទុកដែលមានលើទ្រព្យសម្បត្តិនោះ ។

ញ) ក្រុមហ៊ុន មិនបានធ្វើការធានារ៉ាប់រងបន្តឱ្យបានសមស្របទៅនឹងអាជីវកម្មរបស់ខ្លួន ។

ដ) ផលប្រយោជន៍របស់អ្នកប្រើប្រាស់តម្រូវអោយមានការដកហូតអាជ្ញាបណ្ណនេះ ។

**ប្រការ ១១**

ក) ក្នុងករណីដែលអាជ្ញាប័ណ្ណនឹងត្រូវដកហូត សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមួយដែលបញ្ជាក់អំពីមូលហេតុនៃការដកហូត នឹងត្រូវផ្ញើជូនទៅក្រុមហ៊ុនធានារ៉ាប់រងនោះ ។

ខ) ក្រុមហ៊ុន ត្រូវបានផ្តល់ឱកាសអោយឆ្លើយតបជាលាយលក្ខណ៍អក្សរ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលដប់បួន(១៤)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹង ។

គ) ក្នុងករណីដែលនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ មិនបានទទួលការឆ្លើយតបជាលាយលក្ខណ៍អក្សរ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងចំណុច (ខ) រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងដកហូតអាជ្ញាប័ណ្ណតាមការជូនដំណឹងជាលាយលក្ខណ៍អក្សរ ។

ឃ) ក្នុងករណីដែលបានទទួលការឆ្លើយតបជាលាយលក្ខណ៍អក្សរ បន្ទាប់ពីមានការពិចារណាលើការឆ្លើយតបនេះ ក្រសួងនឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសម្រេចចិត្ត ។

ង) ក្នុងករណីដែលក្រសួងសម្រេចថា មិនដកហូតអាជ្ញាប័ណ្ណទេនោះ ការដាក់លក្ខខណ្ឌទៅលើការបន្តអនុវត្តអាជ្ញាប័ណ្ណនឹងធ្វើឡើងតាមរយៈសេចក្តីជូនដំណឹង ។

**ប្រការ ១២ :** ក្រុមហ៊ុនដែលមិនពេញចិត្តចំពោះការដកហូតអាជ្ញាប័ណ្ណ អាចប្តឹងតវ៉ាចំពោះសេចក្តីសម្រេចនោះទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលដប់បួន(១៤)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសំរេចនេះ ។

ប្រការ ១៣ : រដ្ឋមន្ត្រី និងមន្ត្រីនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ឬបុគ្គលផ្សេងទៀតដែលបំពេញការងារតាមការណែនាំរបស់រដ្ឋមន្ត្រី ឬនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នឹងមិនអាចត្រូវប្តឹងចំពោះការបំពេញ

មុខងារ និងភារៈកិច្ចរបស់ខ្លួន ដែលមានចែងនៅក្នុងប្រការ ១០ នៃប្រកាសនេះ ប្រសិនបើការបំពេញការងារនោះ ត្រូវបានធ្វើឡើងសុចរិតភាព ។

**ជំពូក ៥ : បទប្បញ្ញត្តិផ្សេងទៀត**

**ប្រការ ១៤ :** កាលណាមានការទិញយកភាគហ៊ុននៅក្នុងក្រុមហ៊ុនធានារ៉ាប់រង ដែលធ្វើឱ្យភាគទុនិកកើនចាប់ពីដប់(១០) ភាគរយនៃភាគហ៊ុនរបស់ក្រុមហ៊ុនឡើងទៅ ភាគទុនិកនោះត្រូវផ្ញើជីវប្រវត្តិសង្ខេប និងភ្ជាប់មកជាមួយនូវកម្រងសំណួរ មកនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមទាំងប្រភពនៃដើមទុន ដែលប្រើសម្រាប់ទិញភាគហ៊ុននោះ។ ភាគហ៊ុនដែលបានទិញដោយមិនមានការឯកភាពជាមុននឹងមិនផ្តល់នូវសិទ្ធិអំណាច ឬការទទួលស្គាល់នោះទេ ដរាបណាមិនទាន់បានទទួលការឯកភាព ។

**ប្រការ ១៥ :** ក្នុងករណីមានការតែងតាំងអគ្គនាយកថ្មី ឬមានការផ្លាស់ប្តូរបុគ្គលទាំងឡាយណា (មានបញ្ជាក់នៅក្នុងប្រការ ៤ ) ដែលទទួលខុសត្រូវគ្រប់គ្រងក្រុមហ៊ុនប្រកបដោយប្រសិទ្ធភាព បុគ្គលដែលត្រូវតាំងថ្មីទាំងនោះត្រូវផ្ញើជីវប្រវត្តិសង្ខេប ដោយភ្ជាប់មកជាមួយនូវកម្រងសំណួរ ដែលបានចែងនៅក្នុងប្រការ ៦ មកនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែ ក្នុងករណីដែលមានការតែងតាំង ឬការជំនួសជាបន្ទាន់ ក្រុមហ៊ុនត្រូវផ្តល់ឯកសារទាំងនោះ អោយបានមួយ(១)ខែមុនពេលដែលបុគ្គលនោះចូលកាន់តំណែង ។

**ប្រការ ១៦ :** ប្រសិនបើ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ រកឃើញថាបុគ្គលទាំងឡាយណា ដែលកំពុងបម្រើការងារជាអគ្គនាយក ឬបុគ្គលដែលទទួលខុសត្រូវគ្រប់គ្រងក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព មិនមានសមត្ថភាព ឬមិនមានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ក្នុងការកាន់តំណែងនោះទេ នាយកដ្ឋានអាចបញ្ជាឱ្យដកបុគ្គលនោះពីតំណែង ក្នុងរយៈពេលមួយដែលកំណត់នៅក្នុងលិខិតដោយឡែកមួយ ។ ក្នុងករណីដែលក្រុមហ៊ុនជឿជាក់ថាការបញ្ជាឱ្យដកតំណែងនោះ មានមូលដ្ឋានលើព័ត៌មានមិនពិត ឬជាការភាន់ច្រឡំ អាចប្តឹងជំទាស់នឹងលិខិតបញ្ជានេះ នៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងរយៈពេល ដប់ (១០)ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតបញ្ជានោះ។ ប្រសិនបើ រដ្ឋមន្ត្រីឯកភាពជាមួយនឹងការចេញលិខិតបញ្ជានោះ ក្នុងរយៈពេលដប់(១០)ថ្ងៃ គិតចាប់ពីថ្ងៃប្តឹងជំទាស់លិខិតបញ្ជានោះនឹងត្រូវចូលជាធរមាន។

**ប្រការ ១៧ :** ក្រុមហ៊ុន ត្រូវជូនដំណឹងនូវរាល់ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាពគតិយុត្តិ និងហិរញ្ញវត្ថុ ទៅនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីសុំការអនុម័ត ។ ឯកសារស្នើសុំត្រូវភ្ជាប់មកជាមួយនូវការពិពណ៌នាអំពីមូលហេតុនៃការផ្លាស់ប្តូរប្រតិបត្តិការ ដោយរួមមានព័ត៌មានដូចតទៅ :

ក) ការពង្រីក ឬការកែប្រែសកម្មភាព : ត្រូវផ្តល់ព័ត៌មានដែលមានចែងនៅក្នុងវាក្យខណ្ឌទី ១១ នៃ

ប្រការ ៤ នៃប្រកាសនេះ ។

ខ) ការបន្ថយដើមទុន : ការពិពណ៌នាពីលក្ខខណ្ឌដូចជា លក្ខខណ្ឌគតិយុត្តិ និងគណនេយ្យ ហើយ និងការបង្ហាញតួលេខថ្មីនៃមូលនិធិផ្ទាល់ ព្រមទាំងផលប៉ះពាល់ដល់ប្រតិបត្តិការអាជីវកម្ម នាពេលអនាគត និងអនុបាតប្រុងប្រយ័ត្ន ។

គ) ការផ្លាស់ប្តូរទម្រង់គតិយុត្តិ : សេចក្តីព្រាងវិសោធនកម្មនៃលក្ខន្តិកៈក្រុមហ៊ុន និង ពត៌មានដែល ពាក់ព័ន្ធនឹងគណៈគ្រប់គ្រង។

ឃ) ការផ្លាស់ប្តូរប្រភេទអាជីវកម្ម : សេចក្តីព្រាងវិសោធនកម្មនៃលក្ខន្តិកៈក្រុមហ៊ុន

ក្រុមហ៊ុនត្រូវរាយការណ៍នូវរាល់ការផ្លាស់ប្តូរទាំងអស់នេះ ដល់នាយកដ្ឋានឧស្សាហកម្ម និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងហោចណាស់ពីរ(២)ខែ មុនពេលដែលការ ផ្លាស់ប្តូរកើតឡើង បើពុំនោះទេ សម្រាប់រយៈពេលជូនដំណឹងខ្លីជាងនេះ ត្រូវមានការឯកភាពពី នាយកដ្ឋាន ឧស្សាហកម្មហិរញ្ញវត្ថុ ។

**ប្រការ ១៨ :** ក្រុមហ៊ុនធានារ៉ាប់រង ដែលទទួលបានអាជ្ញាប័ណ្ណ អាចបើកសាខាការិយាល័យក្នុងស្រុកនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដោយគ្រាន់តែមានការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប៉ុណ្ណោះ ។

**ប្រការ ១៩ :** បុគ្គលណាដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះ នឹងត្រូវទទួលការផាកពិន័យជាប្រាក់ ចំនួន ១០លានរៀល បង់ចូលរតនាគារជាតិ ។

**ប្រការ ២០ :** ប្រកាសលេខ ៨៦៤ សហវ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០០១ ត្រូវទុកជានិរាករណ៍ ។ បទប្បញ្ញត្តិ ដទៃទៀតណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ដែរ ។

**ប្រការ ២១ :** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ